ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០២៥/២១ សលា.

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**កម្មវត្ថុ:** គោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ដើម្បីស្នើបញ្ចូលបន្ថែមក្រសួងសាធារណការ និងដឹកជញ្ជូន ចូលជាសមាជិកគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**យោង:** - ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- អនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- សេចក្តីសម្រេចលេខ ១៤៥ សសរ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពជម្រាប ជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបថា វិស័យដឹកជញ្ជូនបានរួមចំណែកយ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍជាតិ ហើយមធ្យោបាយធ្វើដំណើរគ្រប់ប្រភេទ ក៏បានជួយសម្រួលការរស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់មន្ត្រីរាជការ អាជីវករ និងប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់។ ទន្ទឹមនឹងនេះ មធ្យោបាយធ្វើដំណើរក៏ត្រូវបានប្រើប្រាស់ក្នុងការចល័តពលករពីកន្លែងមួយទៅកន្លែងមួយទៀត ឬការជួញដូរមនុស្សពីតំបន់មួយទៅតំបន់មួយទៀតផងដែរ។

ដោយមើលឃើញពីសារៈសំខាន់នៃវិស័យដឹកជញ្ជូន ក្នុងការចូលរួមចំណែកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅប្រទេសកម្ពុជា អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សូមគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម** ដើម្បី:

- ស្នើសុំក្រសួងសាធារណការ និងដឹកជញ្ជូន ចូលជាសមាជិកបន្ថែមរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាពិនិត្យ សម្រេច និង ស្នើសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។

*ថ្ងៃ ចន្ទ ៤ កើត ខែ មាឃ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០២១*

**អនុប្រធានអចិន្ត្រៃយ៍**

**ជូ-ប៊ុនអេង**